**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**សូមគោរពជូន**

**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេច នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !**

នៅក្នុងឱកាសដ៏ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លាដែល **សម្តេចតេជោ** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាទទួលបានបណ្ឌិតកិត្តិយស ពីក្រុមប្រឹក្សាបណ្ឌិតសភាទេសចរណ៍អឺរ៉ុបជា **«មេដឹកនាំពិភពលោកសម្រាប់វិស័យទេសចរណ៍និងការអភិវឌ្ឍ»** ( WORLD LEADER OF TOURISM AND DEVELOPMENT ) ។

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវមនោសញ្ចេតនា សោមនស្សរីករាយ ឥតឧបមា និងអបអរសាទរយ៉ាងក្លៀវក្លាបំផុត ចំពោះ សម្តេចតេជោ **ហ៊ុន សែន** ដែលទទួលបាន បណ្ឌិតកិត្តិយសដ៏វិសេសវិសាលថ្លៃថ្លានេះ គឺជាការផ្តល់នូវមហាកិត្តិយសដ៏ឧត្តុង្គឧត្តមសម្រាប់ **សម្តេច** និងក្រុមគ្រួសាររបស់ **សម្តេច** ក៏ដូចជាសម្រាប់ប្រទេសជាតិ និងប្រជាជនកម្ពុជាទាំងមូល ហើយបណ្ឌិតកិត្តិយសនេះគឺពិតជាស័ក្តិសមចំពោះពលិកម្មដ៏ថ្លៃថ្លារបស់ **សម្តេច** ដែលជានិច្ចកាល **សម្តេច** បានបូជាកម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតី ដើម្បីសន្តិភាព និងការអភិវឌ្ឍ ។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវអំណរសាទរនិងគោរពជូនពរ ចំពោះសម្តេចតេជោ **ហ៊ុន សែន** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** ទាំងអស់ជាទីស្រឡាញ់ សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ បញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

វិថីហ្សកឌឺហ្គោល សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារៈ ០២៣ ៨៨៣ ២៧៤ អ៊ីមែលៈ generalsec@mod.gov.kh